## ធម្មទេសនារបស់លោកបូជាចារ្យ សិលា សួន ហាឡលី
## អភិបូជាបុណ្យព្រះនាងម៉ារីគ្មានជំពាក់បាប នៅព្រះសហគមន៍សន្តសិលា និងសន្តប៉ូល
## ភ្នំពេញថ្មី ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០
## ព្រះនាងម៉ារីជាគំរូសម្រាប់យើង

**អត្ថបទទី១៖ កំណើតពិភពលោក ៣,៩-១៥.២០**

ព្រះជាអម្ចាស់មានព្រះបន្ទូលហៅមនុស្សប្រុសថា៖ «អ្នកនៅឯណា?»។ កណ ៣,៩

**អត្ថបទទី២៖ អេភេសូ ១,៣-៦.១១-១២**

ព្រះអង្គបានជ្រើសរើសយើងក្នុងអង្គព្រះគ្រីស្ត តាំងពីមុនកំណើតពិភពលោកមកម្លេះ ដើម្បីឲ្យយើងបានវិសុទ្ធ។ អភ ១,៤

**ដំណឹងល្អ៖ លូកា ១,២៦-៣៨**

«ចូរមានអំណរសប្បាយឡើង!ព្រះអម្ចាស់គាប់ព្រះហឫទ័យនឹងនាងហើយ ព្រះអង្គគង់ជាមួយនាង»។ លក ១.២៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ខ្ញុំមានអំណរសប្បាយដែលបានថ្វាយអភិបូជានៅមុខព្រះនាងម៉ារី ដូចជាសួនអេដែនម្យ៉ាងដែរ ដោយសារមានទឹក មានដើមឈើ និងមានរូបព្រះនាងម៉ារី។ នៅក្នុងអត្ថបទទីមួយដែលយើងបានស្តាប់អំបាញ់មិញអំពីសួនអេដែន ដែលព្រះជាម្ចាស់បានបង្កើតមនុស្សលោក មានអាដាំនិងអេវ៉ាដែលបានចាញ់ការល្បួងរបស់មាសាតាំង ហើយបានធ្វើឲ្យអំពើបាបចូលក្នុងពិភពលោក។

ថ្ងៃនេះ យើងធ្វើបុណ្យគោរពព្រះនាងម៉ារីដែលគ្មានជំពាក់បាប គម្ពីរដំណឹងល្អដែលយើងស្តាប់ថ្ងៃនេះ នាំឲ្យយើងគិតថាព្រះនាងម៉ារីពិតជាគំរូសម្រាប់យើងជាគ្រីស្តបរិស័ទ។ ព្រះនាងម៉ារីជាគំរូសម្រាប់យើងតាមរបៀបច្រើនយ៉ាង ប៉ុន្តែខ្ញុំសូមចែករំលែកបីចំណុចតែប៉ុណ្ណោះនៅក្នុងយប់នេះ៖

**ចំណុចទីមួយ ចេះស្តាប់បង្គាប់** ព្រះនាងម៉ារីបានទទួលការត្រាស់ហៅពីព្រះជាម្ចាស់ តាមរយៈទេវទូតកាព្រីអែលបានថ្លែងទៅកាន់ព្រះនាងថា នាងត្រូវមានគភ៌។ មុនដំបូងព្រះនាងមានការលំបាក ប៉ុន្តែចុងក្រោយព្រះនាងបានឆ្លើយថា "**នាងខ្ញុំជាអ្នកបម្រើរបស់ព្រះអម្ចាស់ សូមឲ្យបានសម្រេចតាមពាក្យរបស់លោកចុះ**"។ នេះបង្ហាញអំពីព្រះនាងម៉ារីបានស្តាប់បង្គាប់ព្រះជាម្ចាស់ ផ្ទុយពីអាដាំនិងអេវ៉ាដែលយើងបានស្តាប់នៅក្នុងអត្ថបទទីមួយ ដែលមិនបានស្តាប់បង្គាប់ព្រះជាម្ចាស់ទេ។ ព្រះជាម្ចាស់ បានហាមគាត់មិនឲ្យបរិភោគផ្លែឈើដែលដឹងខុសត្រូវ ប៉ុន្តែដោយចាញ់ការល្បួងរបស់មាសាតាំងគាត់បានហូបផ្លែឈើនោះ ដែលធ្វើឲ្យអំពើបាបចូលនៅក្នុងពិភពលោក នាំ

ឲ្យមនុស្សលោកយើងទទួលសេចក្តីស្លាប់។ អាដាំនិងអេវ៉ា មិនបានធ្វើតាមបង្គាប់ព្រះជាម្ចាស់ ផ្ទុយពីព្រះនាងម៉ារីដែលបានស្តាប់បង្គាប់ព្រះជាម្ចាស់ ដែលណែនាំឲ្យពិភពលោកបានទទួលការសង្គ្រោះពីព្រះជាម្ចាស់។ នេះជាចំណុចមួយដ៏សំខាន់សម្រាប់យើង គឺព្រះនាងម៉ារីស្តាប់បង្គាប់។

**ចំណុចទីពីរ រស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់** ក្រោយពេលទទួលព្រះបន្ទូលនៃការត្រាស់ហៅហើយ ព្រះនាងម៉ារីបានយកចិត្តទុកដាក់រស់នៅតាមព្រះបន្ទូលនេះ។ ធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយទទួលព្រះបុត្រារបស់ព្រះអង្គប្រសូតមកនៅក្នុងលោកនេះ។ ក្រោយមក យើងដឹងថាជីវិតរបស់ព្រះនាងម៉ារីយកចិត្តទុកដាក់សម្តែងសេចក្តីស្រឡាញ់ដល់អ្នកដទៃ ព្រះនាងបានទៅសួរសុខទុក្ខយាយអេលីសាប៉ែតដែលជាបងជីដូនមួយ ដើម្បីជួយបម្រើយាយអេលីសាប៉ែតដែលជិតសម្រាលកូនដែរ។ ព្រះនាងម៉ារី បានយកចិត្តទុកដាក់រស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ធ្វើតាមព្រះបន្ទូលរបស់ព្រះអង្គ។

**ចំណុចទីបី នាំព្រះសង្គ្រោះមកដល់ពិភពលោក** ព្រះនាងម៉ារីបានណែនាំឲ្យព្រះកុមារយេស៊ូមកប្រសូតនៅក្នុងលោកនេះ ហើយឲ្យមនុស្សលោកបានទទួលការសង្គ្រោះពីព្រះជាម្ចាស់។

បីចំណុចនេះ ជួយយើងទាំងអស់គ្នាជាគ្រីស្តបរិស័ទ ឲ្យយើងរស់នៅក្នុងកាលៈទេសៈបច្ចុប្បន្ន និងនៅរដូវដែលយើងកំពុងអបអរសាទរព្រះគ្រីស្តយាងមក។ **ឲ្យយើងរៀនស្តាប់បង្គាប់តាមព្រះនាងម៉ារី** យើងស្តាប់បង្គាប់ព្រះជាម្ចាស់ដែលប្រទានព្រះបន្ទូល ដែលប្រទានក្រឹត្យវិន័យផ្សេងៗឲ្យយើង។ ក្នុងរដូវរង់ចាំនេះ ឲ្យយើងយកចិត្តទុកដាក់រស់នៅតាមវិន័យរបស់ព្រះជាម្ចាស់ យើងអាចសួរខ្លួនឯងថា **តើមានអ្វីខ្លះដែលយើងមិនបានធ្វើតាមព្រះអង្គ?** ដោយដឹងថាប្រសិនបើយើងឥតស្តាប់បង្គាប់ព្រះជាម្ចាស់ នាំឲ្យជីវិតរបស់យើងឬអ្នកនៅជុំវិញយើងទទួលមហន្តរាយ។ ចំពោះព្រះសហគមន៍ យើងស្តាប់បង្គាប់សម្តេចប៉ាប លោកអភិបាល លោកបូជាចារ្យដែលជួយណែនាំយើង។ នៅក្នុងសង្គម យើងស្តាប់រាជរដ្ឋាភិបាល ដូចសព្វថ្ងៃក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាលយើងបានចេញលិខិតច្រើន ដើម្បីឲ្យយើងប្រុងប្រយ័ត្នការពារគ្នាទៅវិញទៅមកកុំឲ្យឆ្លងជំងឺកូវីដ១៩។ យើងការពារខ្លួនឯងផង និងការពារកុំឲ្យឆ្លងទៅអ្នកដទៃផង ដោយដឹងថាប្រសិនបើយើងមិនស្តាប់បង្គាប់ទេ នឹងនាំឲ្យប្រទេសកម្ពុជានិងពិភពលោករងទុក្ខលំបាក។ ដូចអាដាំនិងអេវ៉ា គ្រាន់តែជាអំពើបាបរបស់អ្នកទាំងពីរ បានធ្វើឲ្យអំពើបាបចូលនៅក្នុងពិភពលោក។ ជីវិតរបស់យើង ពេលណាយើងឥតស្តាប់បង្គាប់នាំឲ្យសេចក្តីអាក្រក់ចូលនៅក្នុងជីវិតយើង និងដល់អ្នកដែលនៅជុំវិញយើង ធ្វើឲ្យមានសេចក្តីស្លាប់នៅក្នុងសង្គម នៅក្នុងក្រុមគ្រួសាររបស់យើង។ ពេលយើងនិយាយអំពីស្តាប់បង្គាប់មានចំណុចច្រើន នៅក្នុងក្រុមគ្រួសារកូនៗស្តាប់បង្គាប់ឪពុកម្តាយ អ្នកបួសស្តាប់បង្គាប់មេរបស់ខ្លួនដែលជួយណែនាំ ដើម្បីធ្វើឲ្យមានសេចក្តីសុខនៅក្នុងក្រុមគ្រួសារ

របស់យើង។ **រស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់** នៅក្នុងជីវិតរបស់យើង **តើមានព្រះបន្ទូលណាមួយដែលចូលនៅក្នុងជីវិតរបស់ខ្ញុំ ហើយដែលណែនាំឲ្យជីវិតរបស់ខ្ញុំរស់នៅតាមព្រះបន្ទូលនោះដូចព្រះនាងម៉ារី ដែលបានធ្វើឲ្យព្រះបន្ទូលនោះកើតជារូបរាងនៅក្នុងជិវិតរបស់យើង? នាំព្រះសង្គ្រោះដល់មនុស្សលោកទាំងឡាយ** នេះជាគំរូសម្រាប់យើងដែរឲ្យយើងព្យាយាមនាំព្រះយេស៊ូទៅដល់អ្នកដទៃដែលគេមិនទាន់ស្គាល់ តាមរយៈការរស់នៅរបស់យើង តាមរយៈពាក្យសំដីរបស់យើង តាមរយៈកាយវិការដែលយើងធ្វើ។ ដូច្នេះ ពេលណាយើងយកចិត្តទុកដាក់រស់នៅតាមគំរូព្រះនាងម៉ារី យើងអាចណែនាំឲ្យមនុស្សលោកទទួលការសង្គ្រោះពីព្រះជាម្ចាស់។ សូមឲ្យព្រះយេស៊ូប្រសូតនៅក្នុងជីវិតរបស់យើងម្នាក់ ឲ្យយើងម្នាក់ៗក្លាយទៅជាព្រះនាងម៉ារីនៅក្នុងពិភពលោក នៅតាមកន្លែងដែលយើងរស់នៅ ដើម្បីឲ្យគេបានទទួលការសង្គ្រោះពីព្រះអង្គតាមរយៈជីវិតរបស់យើងដែរ។

សូមអរព្រះគុណព្រះជាម្ចាស់ ដែលបានត្រាស់ហៅយើងដូចព្រះនាងម៉ារីដែលបានទទួលការត្រាស់ហៅនេះ។ ព្រះអង្គបានត្រាស់ហៅយើងទាំងពីមុនកំណើតពិភពលោកមក ព្រះអង្គបានបន្សុទ្ធយើង ព្រះអង្គបានលើកលែងទោសឲ្យយើង សូមឲ្យជីវិតរបស់យើងនៅក្នុងរដូវអបអរសាទរនេះ ឲ្យជីវិតរបស់យើងរស់នៅបានវិសុទ្ធរួមជាមួយព្រះនាងម៉ារី។ តាមរយៈព្រះនាងម៉ារី សូមព្រះជាម្ចាស់ការពារយើងទាំងអស់គ្នាឲ្យរួចពីសេចក្តីអាក្រក់ ជាពិសេសគ្រោះថ្នាក់ដោយសារជំងឺឆ្លងបច្ចុប្បន្នគឺជំងឺកូវីដ១៩ ឲ្យប្រទេសកម្ពុជាយើងនិងពិភពលោកទាំងមូល បានឆ្លងផុតពីគ្រោះកាចនេះយ៉ាងឆាប់ៗផង។ អាម៉ែន៕